# ការប្រជុំពេញអង្គលើកទី ៦
# កំនត់ដើម្បីពិភាក្សាពីការចូលរួមនៃដើមបណ្តឹងរដ្ឋប្បវេណីនាពេលអនាគត

*ម៉ៃ ខឹល សាលីបា*

*ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ខី សុជាតា*

អង្គជំនុំជម្រះសាលាដំបូងកាត់ក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានសម្រាកមួយសប្តាហ៍ ទន្ទឹមនិងពេលដែលតុលាការទុកឲ្យដើម្បីធ្វើការប្រជុំពេញអង្គនៅសប្តាហ៍នេះ ។ កិច្ចប្រជុំពេញអង្គនៅក្រោមអធិបតីភាពលោក គង់ ស្រ៊ឹម និងអនុប្រធានអន្តរជាតិលោកស្រីចៅក្រម ស៊ីលវៀ ខាតរាយជ៍ បានធ្វើសេចក្តីថ្លែងការណ៍ដំបូងនៅពេលមានកិច្ចប្រជុំពេលព្រឹក ដែលត្រូវបានបើកសន្និសីទកាសែតមុនពេលបិទកិច្ចពិភាក្សាសម្ងាត់ ។

### របៀបវារៈ

សេចក្តីរាយការណ៍ពីរបៀបវារៈសម្រាប់កិច្ចប្រជុំពេញអង្គនេះ រួមបញ្ចូលទាំងការពិនិត្យច្បាប់ទាំងឡាយ ដែលទាក់ទងទៅនឹងវិធានការណ៍ការពារភស្តុតាង ពេលកំណត់នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី វិធានការណ៍ដែលគាត់តែងឡើងដើម្បីជួយសម្រួលដល់នីតិវិធី នៅពេលដែលមានបណ្តឹងឧទ្ធរណ៍ទៅនឹងដីការដំណោះស្រាយ និងនីតិវិធីមុនពេលបើកសវនាការដោយអង្គជំនុំជម្រះសាលាកំពូល ។ ប្រហែលជារឿងសំខាន់ៗកាន់តែច្រើន ដែលនឹងត្រូវលើកយកមកពិភាក្សាទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី និងគំរូនៃការចូលរួមរបស់ជនរងគ្រោះក្នុងនីតិវិធីនាពេលអនាគត ។

តុលាការ ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលជាច្រើនផ្សេងទៀតបានបញ្ចេញនូវចម្ងល់ ដែលជាគំរូនៃការចូលរួមរបស់ជនរងគ្រោះ ដូចជាសព្វថ្ងៃវាស្ថិតនៅក្នុងលក្ខណៈដាច់ដោយឡែក មិនអាចរក្សាបានចំពោះករណីទី២ ។ ចៅក្រម ខាតរាយជ៍ បានបញ្ចេញមតិចំពោះអង្គជំនុំជម្រះថា នីតិវិធីដែលពាក់ពន្ធ័នឹងជនរងគ្រោះក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីធ្លាប់មានភាពរាំងស្ទះដល់ដំណើរការតុលាការ ប៉ុន្តែជារឿយៗ មិនមានចេតនាធ្វើឲ្យមានការយឺតយ៉ាវដល់នីតិវិធីតុលាការទេ ។ ជាលទ្ធផល លោកស្រីចៅក្រម បានពន្យល់ពីភាពប្រឆាំងទៅនឹងការចង់បានពេលវេលាយុត្តិធម៌មួយរបស់ជនរងគ្រោះចំពោះការឈឺចាប់របស់គាត់ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានព្យាករណ៍ថា ប្រសិនបើមេធាវីការពារក្តីករណី

០០២ បដិសេធសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មួយភាគបីនៃចំនួន ២៥០០ពាក្យបណ្តឹងដែលបានរំពឹងទុកនោះ តុលាការនឹងត្រូវចំណាយពេលសម្រាប់ភាពមិនចុះសំរុងនេះលើសពី៨ខែ ដើម្បីដោះស្រាយទំនាស់ទាំងនេះ ។ ផ្ទុយពីការបដិសេធនេះ ការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី គឺជាការពិចារណាដើម្បីឈានទៅដល់ទស្សនវិស័យមួយដ៏សំខាន់នៃសាលាជម្រះក្តី និងជាអ្នកតំណាងដល់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងបំណងធានាថា សិទ្ធនិងផលប្រយោជន៍កូនក្តីរបស់គាត់ ត្រូវបានលើកកំពស់នៅក្នុងហេតុការណ៍ផ្លាស់ប្តូរផ្សេងៗនៃវិធានផ្ទៃក្នុង ។

មានចម្ងល់ជាច្រើនទាក់ទងនឹងផលប្រយោជន៍របស់ភាគីទាំងឡាយ គណៈកម្មាការនីតិវិធី និងវិធានផ្ទៃក្នុងបានជួបគ្នានៅសប្តាហ៍មុន ដើម្បីពិនិត្យឡើងវិញនូវវិធានទាំងឡាយដែលការពារដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសំណើឲ្យមានកិច្ចប្រជុំពេញអង្គ ។ ទោះជាយ៉ាងណាក៏ដោយ ក៏គ្មានការកែប្រែវិធានផ្ទៃក្នុងណាត្រូវបានរំពឹងទុកថា នឹងបានអនុម័តនៅពេលធ្វើសេចក្តីសន្និដ្ឋានក្នុងកិច្ចប្រជុំទេ ដោយហេតុថាការពិភាក្សាត្រូវបានរំពឹងទុកថានឹងធ្វើទៅតាមដំណើរ ។ ប៉ុន្តែ កិច្ចពិភាក្សានឹងផ្តល់ជាមូលដ្ឋានមួយសម្រាប់កែប្រែវិធានផ្ទៃក្នុងនាពេលអនាគត ទន្ទឹមនឹងពេលដែលការចាប់ផ្តើមនៃករណី០០២ ខិតជិតមកដល់ ។

## សេចក្តីសង្ខេបនៃកិច្ចប្រជុំពេញអង្គ

តុលាការបើកកិច្ចប្រជុំពេញអង្គរៀងរាល់ ៦ខែម្តង ដើម្បីសំរេចលើបញ្ហាទាំងឡាយណា ដែលពាក់ពន្ធ័ទៅនឹងមុខនាទីវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ។ ខណៈពេលប្រជុំ តុលាការពិនិត្យឡើងវិញនិងកែប្រែចំណុចណាដែលចាំបាច់នៃវិធានផ្ទៃក្នុង ។ ម្តងក្នុងមួយឆ្នាំ តុលាការបានអនុម័តរបាយការណ៍មួយ ដែលរៀបចំដោយការិយាល័យរដ្ឋបាល ដើម្បីផ្ញើទៅឧត្តមក្រុមប្រឹក្សាអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា និងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

កិច្ចប្រជុំពេញអង្គត្រូវបានចូលរួមដោយសហព្រះរាជអាជ្ញានិងអ្នកបំរុង ប្រធានអង្គភាពការពារក្តី ប្រធានសមាគមន៍ជនរងគ្រោះ និងប្រធាននិងអនុប្រធានការិយាល័យរដ្ឋបាល ។ ប៉ុន្តែ មានតែសហចៅក្រមស៊ើបអង្កេតនិងចៅក្រមនៃអង្គជំនុំជម្រះទេ ដែលត្រូវបានផ្តល់សិទ្ធិឲ្យបោះឆ្នោតចំពោះសំណើរផ្លាស់ប្តូរនីតិវិធីក្នុងវិធានផ្ទៃក្នុង ឬសេចក្តីសំរេចផ្សេងៗដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំពេញអង្គ ។ ដូចគ្នានឹងការផ្លាស់ប្តូរចំពោះសេចក្តីសំរេចនិងវិធាន គឺតម្រូវឲ្យមានការបោះឆ្នោត ចេញពីសម្លេងភាគច្រើនលើសលុប ១៨/១៩ ពីចៅក្រម ។ (សហព្រះរាជអាជ្ញាត្រូវបានទទួលសិទ្ធិបោះឆ្នោត ដែលមិនមែនជាវិធាននៃនីតិវិធី ទាក់ទិនទៅនិងស្ថាប័នរដ្ឋបាលនៃ អ.វ.ត.ក តាមរយៈស្ថានភាពរបស់ពួកគេដូចជាមន្ត្រីតុលាការនៅក្រោមច្បាប់កម្ពុជា) ។